សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញ
សមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
២១ វិច្ឆិកា ២០១៤

- សូមគោរព លោក ងី សិទ្ធិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង!
- សូមគោរព លោក អ៊ុង ប៉ូឡា នាយកប្រតិបត្តិនៃអង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍!
- សូមគោរព លោក សារុន ចុង នាយកប្រតិបត្តិអង្គការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គម!
- សូមគោរព អស់លោក លោកស្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួនបី សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ដែលគម្រោងទីមួយគឺគម្រោងសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាបឹងធុង ក្នុងស្រុកបវេល ខេត្តបាត់ដំបង គម្រោងទីពីរគឺ គម្រោងសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាទួលគ្រោះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ និងគម្រោងទីបីគឺគម្រោងសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាបឹងត្នោត ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។

គម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលបំណងដើម្បីកែលម្អធ្វើអោយប្រសើរឡើងបរិស្ថាននៃការសិក្សាដល់សិស្សានុសិស្ស និងគ្រូបង្រៀនទៅតាមតំបន់គម្រោងនិមួយៗ។ ខ្ញុំមានជំនឿថា ការកែលម្អធ្វើអោយប្រសើរឡើងវិស័យអប់រំ គឺជាគន្លឹះមួយសម្រាប់អនាគតនៃការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ វាមានសារៈសំខាន់ណាស់ក្នុងការវិនិយោគក្នុងវិស័យអប់រំដែលជាចក្ខុវិស័យដ៏វែងឆ្ងាយ។ វិស័យអប់រំ គឺជាវិស័យអាទិភាពមួយនៃបណ្តាវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ វិស័យនេះ ក៏ជាវិស័យអាទិភាពមួយរបស់ជប៉ុនផងដែរ ក្នុងការជួយដល់ប្រទេសកម្ពុជា។ ដោយពិតទៅ ជប៉ុនបានគាំទ្រយ៉ាងពេញទំហឹងដល់វិស័យអប់រំនៅកម្ពុជាជាងពីរទសវត្សរ៍កន្លងមកហើយ តាមរយៈការសាងសង់អគារសិក្សា និងការផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀន។

ជំនួយទីមួយ មានថវិកាចំនួន ៨៨,០៣៤ ដុល្លារអាមេរិក ផ្តល់ជូនដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង សម្រាប់ការសាងសង់អាគារសិក្សាមួយខ្នងរួមជាមួយនឹងបង្គន់អនាម័យ និងការបំពាក់សំភារៈសិក្សាដែលចាំបាច់ នៅសាលាបឋមសិក្សាបឹងធុង ក្នុងស្រុកបវេល ខេត្តបាត់ដំបង។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សបឋមសិក្សាចំនួនជាង៣០០នាក់ នឹងអាចរីករាយក្នុងការសិក្សាប្រកបដោយសុវត្ថិភាព និងជាសុខភាពក្នុងថ្នាក់រៀនថ្មីនេះ។

ជំនួយទីពីរ មានថវិកាចំនួន ៨៦,០០៥ ដុល្លារអាមេរិកផ្តល់ជូនដល់អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍ សម្រាប់ការសាងសង់អគារសិក្សាមួយខ្នងរួមជាមួយនឹងបង្គន់អនាម័យ និងការបំពាក់សំភារៈសិក្សាដែលចាំបាច់ នៅ

សាលាបឋមសិក្សាទួលគ្រោះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ គម្រោងនេះ សង្ឃឹមថានឹងជួយកែលម្អបរិស្ថាននៃការសិក្សាជាមួយនឹងថ្នាក់រៀនថ្មីនេះ សម្រាប់សិស្សានុសិស្សប្រមាណ ១៤០នាក់។

ជំនួយទីបី មានថវិកាចំនួន ៩៨,៨៣៨ ដុល្លារអាមេរិក ផ្តល់ជូនដល់អង្គការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គម ដោយការសាងសង់នូវអគារសិក្សាមួយខ្នងរួមជាមួយនឹងបង្គន់អនាម័យ និងការបំពាក់សំភារៈសិក្សាដែលចាំបាច់ នៅសាលាបឋមសិក្សាបឹងត្នោតក្នុងស្រុកបាកានខេត្តពោធិ៍សាត់។ គម្រោងនេះ នឹងផ្តល់នូវសុវត្ថិភាព និងបរិស្ថាននៃការសិក្សាប្រកបដោយផាសុខភាពសម្រាប់សិស្សានុសិស្សប្រមាណ ៤៣០ នាក់ ដែលបច្ចុប្បន្នកំពុងប្រើប្រាស់អគារសិក្សាដែលមានលក្ខណៈចាស់ទ្រុឌទ្រោម។

គម្រោងសាងសង់ទាំងនេះ នឹងចាប់ដំណើរការនាពេលឆាប់ៗនេះ ហើយសង្ឃឹមថា នឹងអាចសាងសង់រួចក្នុងរយៈពេលមួយឆ្នាំ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងទាំងនេះ នឹងត្រូវបានអនុវត្តទៅដោយរលូន។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសំណង់ទាំងអស់ដែលត្រូវបានសាងសង់ដោយគម្រោងទំងនេះ នឹងត្រូវបានថែទាំងយ៉ាងត្រឹមត្រូវ ដើម្បីប្រើប្រាស់បានយូរអង្វែង និងផ្តល់ជាអត្ថប្រយោជន៍ដល់សិស្សានុសិស្ស និងគ្រូបង្រៀនតាមដែលអាចទៅរួច។ ខ្ញុំក៏សង្ឃឹមផងដែរថា គម្រោងទាំងនេះ នឹងជួយពង្រឹងនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!